**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ ២២២០៨.១ អពដ

L20200914001 | TD2432

ថ្ងៃ អង្គារ ០៥ កើត ខែ អស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០២០

# សេចក្តីជូនដំណឹង

## ស្តីពី

## ការពន្យារកាលបរិច្ឆេទកំណត់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing)

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់អ្នកជាប់ពន្ធទាំងអស់ជ្រាបថា តបតាមសំណូមពររបស់វិស័យឯកជនឱ្យផ្តល់ពេលវេលាបន្ថែមក្នុងការត្រៀមខ្លួននិងបណ្តុះបណ្តាលបុគ្គលិក ដើម្បីអាចប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing) ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសម្រេចពន្យារកាលបរិច្ឆេទកំណត់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing) រហូតដល់ដំណាច់ឆ្នាំ ២០២០ ដោយចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ ២០២១ តទៅ។

ទន្ទឹមនឹងនេះ អ្នកជាប់ពន្ធដែលមិនទាន់ត្រៀមខ្លួនរួចរាល់ អាចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំខែ ស្របតាមទម្រង់លិខិតប្រកាសដែលកំពុងអនុវត្តជាធរមាន និងបន្តប្រើប្រាស់ប្រព័ន្ធអនឡាញសម្រាប់គ្រប់គ្រងអាករលើតម្លៃបន្ថែម (Online-VAT Refund and Online-VAT Credit) ស្របតាមសេចក្តីណែនាំលេខ ០០១ សហវ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩។ ដោយឡែក អ្នកជាប់ពន្ធដែលបានចាប់ផ្តើមដាក់លិខិតប្រកាសតាមរយៈប្រព័ន្ធ E-Filing អាចបន្តប្រើប្រាស់ប្រព័ន្ធនេះជាធម្មតា។

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់ថា ការពន្យារកាលបរិច្ឆេទកំណត់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing) នឹងច្បាស់ជាជួយសម្រួលនិងផ្តល់លទ្ធភាពគ្រប់គ្រាន់ដល់អ្នកជាប់ពន្ធទាំងអស់ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធឱ្យត្រឹមត្រូវ ស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

អគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855) 23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh